GLOBAL PARTNERSHIP for EDUCATION

United Nations Educational, Scientific and Cultural Organization

unicef for every child

# ភាពជាដៃគូសកលសម្រាប់ការអប់រំ
# អនុម័តហិរញ្ញប្បទានឥតសំណងក្នុងទឹកប្រាក់ ២០,៦ លានដុល្លារអាមេរិក ដើម្បីពង្រឹងប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជា

**រាជធានីភ្នំពេញ ប្រទេសកម្ពុជា ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨** – ក្រុមប្រឹក្សាភិបាលនៃភាពជាដៃគូសកលសម្រាប់ការអប់រំបានអនុម័តហិរញ្ញប្បទានឥតសំណងក្នុងទឹកប្រាក់ចំនួន ២០,៦ លានដុល្លារអាមេរិក ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការលើកកម្ពស់គុណភាពអប់រំនៅបឋមសិក្សា។

ហិរញ្ញប្បទានឥតសំណងនេះនឹងផ្តល់ប្រយោជន៍ជាពិសេសដល់កុមារមកពីគ្រួសារជួបការលំបាកក៏ដូចជាបង្កើនប្រសិទ្ធភាពនៃការបង្រៀន ពង្រឹងភាពដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំរួមមាន៖ គ្រូបង្រៀន នាយកសាលា ព្រមទាំងអ្នកផ្តល់សេវាអប់រំនៅតាមមូលដ្ឋាន និងនៅថ្នាក់ជាតិ។

នេះជាលើកទីបីហើយដែលភាពជាដៃគូសកលសម្រាប់ការអប់រំ (ហៅកាត់ថា GPE) បានផ្តល់ហិរញ្ញប្បទានឥតសំណងសម្រាប់ប្រទេសកម្ពុជា។ GPE នឹងនាំមកនូវកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា អង្គការយូណេស្កូ និងអង្គការយូនីសេហ្វ ព្រមទាំងដៃគូអភិវឌ្ឍន៍ដទៃទៀតក្នុងការជួយដល់វិស័យអប់រំ ដូចជាសហភាពអឺរ៉ុប ប្រទេសស៊ុយអ៊ែត និងទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ។

**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** បានស្វាគមន៍ការបន្តភាពជាដៃគូនេះដែលនឹងជួយកុមារជួបការលំបាកទាំងអស់ឲ្យមានលទ្ធភាពរៀនសូត្រ និងអភិវឌ្ឍកាន់តែល្អប្រសើរ។

ឯកឧត្តមមានប្រសាសន៍ថា *"ភាពជាដៃគូសកលសម្រាប់ការអប់រំ បានរួមចំណែកដ៏សំខាន់ដល់វិស័យអប់រំនៅកម្ពុជាចាប់តាំងពីឆ្នាំ ២០០៦មក។ ការជួយគាំទ្របន្ថែមរបស់ GPE នេះនឹងផ្តល់លទ្ធភាពឱ្យយើងអាចពង្រីក និងពង្រឹងគ្រូបង្រៀនរបស់យើងឱ្យកាន់តែមានសមត្ថភាពបន្ថែមទៀត ដើម្បីផ្តល់ឱ្យកុមារដែលជួបការលំបាកនូវលក្ខខណ្ឌដែលពួកគេត្រូវការក្នុងការរៀនសូត្រ និងរីកចម្រើន"*។

លទ្ធផលនៃកម្មវិធី GPE ថ្មីនេះនឹងត្រូវសម្រេចតាមរយៈសមាសភាគចំនួនពីរ៖ សមាសភាគទី១ ក្នុងទឹកប្រាក់ចំនួន ១៤,៤ លានដុល្លារអាមេរិកសម្រាប់*កម្មវិធីពង្រឹងការអប់រំគ្រូបង្រៀននៅកម្ពុជា (STEPCam)*, ដែលផ្តោតលើគ្រូបង្រៀននៅកម្រិតថ្នាក់ដំបូងនៃបឋមសិក្សា និងគ្រូឧទ្ទេសនៅតាមសាលាគរុកោសល្យខេត្ត។ សមាសភាគទី២ មានទឹកប្រាក់ចំនួន ៦,២ លានដុល្លារអាមេរិក ដែលប្រើប្រាស់គំរូផ្តល់ថវិកាផ្អែកតាមលទ្ធផលដើម្បីផ្សារភ្ជាប់ទៅនឹងលទ្ធផលការងារ សំដៅលើកកម្ពស់សមធម៌ ប្រសិទ្ធភាព និងលទ្ធផលសិក្សារបស់សិស្ស។

**លោកស្រី Alice Albright ប្រធានប្រតិបត្តិនៃភាពជាដៃគូសកលសម្រាប់ការអប់រំ** មានប្រសាសន៍ថា៖ *"ប្រទេសកម្ពុជាជាដៃគូរបស់ GPE ចាប់តាំងពីឆ្នាំ ២០០៦ មកបានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះវិស័យអប់រំដើម្បីធ្វើយ៉ាងណាឱ្យវិស័យនេះកាន់តែមានភាពរឹងមាំ និងកាន់តែមានសមធម៌សម្រាប់កុមារជាច្រើននាក់ទៀត។ តាមរយៈហិរញ្ញប្បទានឥតសំណងលើកទី៣នេះ GPE នឹងជួយពន្លឿនវឌ្ឍនភាពនៃវិស័យអប់រំនៅកម្ពុជាឱ្យមានសមិទ្ធផលគួរឱ្យកត់សម្គាល់បន្ថែមទៀត"*។

*កម្មវិធីពង្រឹងការអប់រំគ្រូបង្រៀននៅកម្ពុជា* ដែលនឹងត្រូវអនុវត្តក្នុងភាពជាដៃគូរវាងក្រសួងអប់រំ យុវជន និងកីឡា និងអង្គការយូណេស្កូ គាំទ្រដល់ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀនរបស់ក្រសួង និងផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀនកម្រិតថ្នាក់ដំបូង។ កម្មវិធីនេះនឹងជួយក្រសួងអប់រំ យុវជន និងកីឡាក្នុងការរៀបចំនិងអនុវត្តប្រព័ន្ធដែលមានចីរភាពមួយ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្រៀនស្របតាមគន្លងអាជីពគ្រូបង្រៀន ដែលនឹងត្រូវរៀបចំឡើងជាផ្នែកមួយនៃផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន។

**លោកស្រី Anne Lemaistre តំណាងអង្គការយូណេស្កូប្រចាំនៅកម្ពុជា** មានប្រសាសន៍ថា៖ *"ការបណ្តុះបណ្តាលគ្រូមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់គុណភាពអប់រំ។ ការគាំទ្ររបស់ GPE ដល់ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនគឺជាការរួមចំណែកដ៏សំខាន់ក្នុងការពង្រឹងគុណភាពអប់រំ ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ (SDG4)"*។

សមាសភាគផ្សារភ្ជាប់លទ្ធផលនឹងត្រូវអនុវត្តក្នុងភាពជាដៃគូរវាងក្រសួងអប់រំ យុវជន និងកីឡា និងអង្គការយូនីសេហ្វ តាមរយៈមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍន៍សមត្ថភាព (CDPF) ដែលកំពុងតែអនុវត្តនាពេលបច្ចុប្បន្ននេះ។ CDPF គឺជាមូលនិធិពហុដៃគូបង្កើតឡើងក្នុងគោលបំណងជួយពង្រឹងសមត្ថភាពផ្នែករៀបចំគោលនយោបាយ កសាងផែនការថវិកា បុគ្គលិក ការអប់រំប្រកបដោយបរិយាបន្ន និងសមធម៌ យេនឌ័រនៃភាពដឹកនាំ ឆ្ពោះទៅរកការផ្តល់សេវាគុណភាពអប់រំប្រកបដោយសមធម៌ បរិយាបន្ន សម្រាប់កុមារទាំងអស់នៅកម្ពុជា។

**លោកស្រី Debora Comini តំណាងអង្គការយូនីសេហ្វប្រចាំនៅកម្ពុជា - ដែលជាទីភ្នាក់ងារសម្របសម្រួល GPE** មានប្រសាសន៍ថា៖ *"ការរួមចំណែករបស់ GPE ចំពោះមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍន៍សមត្ថភាពនឹងចូលរួមសម្រេចវឌ្ឍនភាពការងារចម្បងៗនៃប្រព័ន្ធអប់រំ ដូចជាការរៀបចំក្របខណ្ឌអាហារូបករណ៍សម្រាប់បឋមសិក្សា ដែលផ្តោតការយកចិត្តទុកដាក់លើតម្រូវការរបស់កុមារជួបការលំបាក បង្កើនប្រសិទ្ធភាពនៃការអនុវត្តផែនការ អភិវឌ្ឍន៍សាលារៀន និងផ្តល់ការណែនាំដល់គ្រូបង្រៀនដើម្បីពង្រឹងគុណភាពនៃការសិក្សារបស់សិស្ស"*។

**លោក Franck Viault អគ្គកុងស៊ុល – ដែលជាប្រធានផ្នែកកិច្ចសហប្រតិបត្តិការរបស់សហភាពអឺរ៉ុបប្រចាំនៅកម្ពុជា** មានប្រសាសន៍ថា៖ *"សហភាពអឺរ៉ុបនិងរដ្ឋជាសមាជិកបានរួមវិភាគទាន៧១,៥% នៃហិរញ្ញប្បទានរបស់ GPE ចាប់តាំងពីការចាប់ផ្តើម ហើយយើងមានមោទនភាពជាខ្លាំងចំពោះកិច្ចសហប្រតិបត្តិការនេះ។ ការគាំទ្ររបស់ GPE ជាការបំពេញបន្ថែមលើកិច្ចព្រមព្រៀងទ្វេភាគីដ៏មានសារៈសំខាន់ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំគ្រប់កម្រិតនៅកម្ពុជា"*។

ប្រព័ន្ធអប់រំនៅកម្ពុជាសម្រេចបាននូវវឌ្ឍនភាពជាបន្តបន្ទាប់គួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ អត្រាពិតនៃការសិក្សានៅបឋមសិក្សាកើនឡើងពី ៨៧% ក្នុងឆ្នាំ ២០០១ ដល់ ៩៤% ក្នុងឆ្នាំ ២០១៥ ហើយការចុះឈ្មោះចូលរៀនក្នុងកម្មវិធីអប់រំកុមារតូចនៅទូទាំងប្រទេសកើនឡើងជិត ២,៥ ដង ក្នុងចន្លោះពីឆ្នាំ ២០០៥ ដល់ ២០១៥។

អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិក៏មានការកើនឡើងផងដែរ ពី ១៩% ដល់ ៥១% ក្នុងចន្លោះពីឆ្នាំ ២០០១ ដល់ ២០១៥ ប៉ុន្តែចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីបង្កើនអត្រាបញ្ចប់ការសិក្សា។ ដោយសារការខិតខំប្រឹងប្រែងយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាល ប្រទេសកម្ពុជាបានលុបបំបាត់គម្លាតយេនឌ័រនៅកម្រិតបឋមសិក្សា។ ដោយឡែកនៅកម្រិតមធ្យមសិក្សាវិញ ចំនួនសិស្សស្រីមានច្រើនជាងចំនួនសិស្សប្រុស។

ខណៈដែលអត្រាត្រួតថ្នាក់នៅបឋមសិក្សានៅកម្ពុជាថយចុះពី ១២% មកក្រោម ៧% នៅចន្លោះឆ្នាំសិក្សា ២០០៤/២០០៥ និង២០១៥/២០១៦ អត្រាត្រួតថ្នាក់ទី១ នៅមានកម្រិតខ្ពស់នៅឡើយ ពោលគឺ ១១,៦%។ ហិរញ្ញប្បទានឥតសំណងរបស់ GPE នេះនឹងជួយដល់ស្រុកមួយចំនួនដែលកំពុងជួបការលំបាកជាងគេ។

អង្គការយូណេស្កូគឺជាភ្នាក់ងារគ្រប់គ្រងហិរញ្ញប្បទានឥតសំណងរបស់ GPE នៅកម្ពុជាផ្នែកសមាសភាគការអប់រំគ្រូបង្រៀន ដោយឡែកអង្គការយូនីសេហ្វគឺជាភ្នាក់ងារគ្រប់គ្រងហិរញ្ញប្បទានឥតសំណងផ្នែកសមាសភាគផ្សារភ្ជាប់នឹងលទ្ធផល។ តាមរយៈការសហការជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀត ភ្នាក់ងារទាំងពីរនឹងគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអនុវត្តកម្មវិធីនេះ។

#######

**អំពីភាពជាដៃគូសកលសម្រាប់ការអប់រំ៖** ភាពជាដៃគូសកលសម្រាប់ការអប់រំធ្វើការងារជាមួយប្រទេសកំពុងអភិវឌ្ឍជាង៦០ដើម្បីធានាយ៉ាងណាឱ្យកុមារគ្រប់រូបទទួលបានការអប់រំកម្រិតមូលដ្ឋានប្រកបដោយគុណភាព ដោយផ្តោតអាទិភាពលើកុមារមកពីគ្រួសារមានជីវភាពក្រីក្របំផុត កុមារងាយរងគ្រោះជាងគេ និងកុមាររស់នៅក្នុងប្រទេសដែលរងផលប៉ះពាល់ដោយសារការបែកបាក់ និងជម្លោះ។ កម្មវិធី GPE កៀគរហិរញ្ញប្បទានដើម្បីលើកកម្ពស់ការសិក្សា និងសមធម៌តាមរយៈការកសាងប្រព័ន្ធអប់រំឱ្យកាន់តែរឹងមាំ។ ក្នុងនាមជាអង្គការសាកលតែមួយគត់ ដែលផ្តោតការយកចិត្តទុកដាក់ទាំងស្រុងលើការលើកកម្ពស់ការអប់រំ GPE ប្រមូលផ្តុំរដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍ និងរដ្ឋាភិបាលនៃប្រទេសផ្តល់ហិរញ្ញប្បទាន ទីភ្នាក់ងារអភិវឌ្ឍន៍ពហុភាគី និងទីភ្នាក់ងារមនុស្សធម៌ព្រមទាំងស្ថាប័នមកពីវិស័យឯកជន សប្បុរសជន សង្គមស៊ីវិល និងអ្នកមានវិជ្ជាជីវៈបង្រៀនឱ្យធ្វើការងាររួមគ្នា។

**ខ្លឹមសារដែលពាក់ព័ន្ធ៖**

ការងាររបស់ GPE នៅកម្ពុជា

វីដេអូ៖ https://www.globalpartnership.org/blog/investing-early-childhood-education-cambodias-future-success

**ព័ត៌មានទំនាក់ទំនងសម្រាប់អ្នកសារព័ត៌មាន៖**


**នៅទីក្រុងភ្នំពេញ៖**

លីម សុធា, ក្រសួងអប់រំ យុវជន និងកីឡា៖ lim.sothea@moeys.gov.kh

អាង សូផា, អង្គការយូណេស្កូនៅកម្ពុជា៖ s.ang@unesco.org

Iman Morooka, អង្គការយូនីសេហ្វនៅកម្ពុជា៖ imorooka@unicef.org

សឿម យូរ៉ា, អង្គការយូនីសេហ្វនៅកម្ពុជា៖ ysoeum@unicef.org

Muna Haq, សហភាពអឺរ៉ុបនៅកម្ពុជា៖ Muna.HAQ@ext.eeas.europa.eu

**នៅទីក្រុងវ៉ាស៊ីតោន៖**

Alexandra Humme៖ ahumme@globalpartnership.org